# គន្លឹះខ្លះ ៗ ដើម្បីយល់អំពីទំនាក់ទំនង ដែលមានតាំងពីយូរលង់ រវាងប្រទេសខ្មែរ និង ភូមិភាគខាងត្បូងនៃប្រទេសថៃ[*]

ដោយ ដាវរឿង វិទ្យារដ្ឋ
គ្រូបង្រៀន ដេប៉ាតឺម៉ង់ភាសាសៀម មហាវិទ្យាល័យអក្សរសាស្ត្រ
សាកលវិទ្យាល័យចុឡាលង្ករណ៍ ក្រុងបាងកក (ប្រទេសថៃ)
និង មីស្ហែល បុទ្ធី អង់តែល្ម
គ្រូសន្និសីទ វិទ្យាស្ថានជាតិនៃភាសានិងអារ្យធម៌នៃបូព៌ាប្រទេស
ក្រុងប៉ារីស (ប្រទេសបារាំង)

**ប្រជាជននៅត្រើយទាំងពីរនៃឈូងសមុទ្រសៀម** គឺត្រើយខាងកើតនៃភូមិភាគខាងត្បូងរបស់ប្រទេសថៃ និង ដែនដីតាមមាត់សមុទ្រនៃប្រទេសកម្ពុជា (និងប្រទេសវៀតណាមខាងត្បូង ដែលជាអាណាខេត្តរបស់ប្រទេសកម្ពុជាក្នុងអតីតកាល) ធ្លាប់មានទំនាក់ទំនងគ្នាទៅវិញទៅមកតាំងពីយូរលង់ណាស់មកហើយ ប្រហែលតាំងពីសម័យបុរេប្រវត្តិមកម៉្លេះ ។ ការណ៍នេះ បានបន្សល់ទុកនូវស្នាកស្នាមមួយចំនួនខាងភាសាសាស្ត្រ និង វប្បធម៌ក្នុងភូមិភាគទាំងនេះ ។ នៅក្នុងអត្ថបទនេះ យើងខ្ញុំសូមចង្អុលបង្ហាញនូវកស្តុតាងខ្លះៗ ដែលអាចជាគន្លឹះក្នុងការយល់ដឹងអំពីទំនាក់ទំនងទាំងនេះ ជាពិសេសលក្ខណៈខ្មែរក្នុងភូមិភាគខាងត្បូងនៃប្រទេសថៃ ។

## ការតាំងលំនៅឋានរបស់ប្រជាជនទាំងឡាយក្រៅពីខ្មែរ ក្នុងភាគខាងត្បូងនៃប្រទេសថៃ

ការណ៍ដែលភូមិភាគខាងត្បូងនៃប្រទេសថៃ បានក្លាយជាភូមិភាគមួយដែលមានប្រជាជននិយាយភាសាថៃ បានចាប់ផ្តើមយ៉ាងយូរបំផុតនៅសតវត្សរ៍ទី ១៣ ត្បិតសិលាចារឹកព្រះបាទរាមកំហែង [(១)] បានថែងថា នគរស្រីធម្មរាជជាស្រុកចំណុះរបស់ក្រុងសុខោទ័យ ព្រះអង្គក៏ទទួលស្គាល់ផងដែរថា នគរស្រីធម្មរាជនេះ ល្បីឈ្មោះជាមជ្ឈមណ្ឌលសិក្សាខាងព្រះពុទ្ធសាសនាមកពីកោះលង្កា ។ តែយើងមិនអាចដឹងបានអំពីការតាំងលំនៅឋានរបស់ប្រជាជនថៃជាចំនួនធំសម្បើម ក្នុងភូមិភាគខាងត្បូងនៃប្រទេសថៃឡើយ ។ មានមហាថេរសង្ឃរាជដ៏ធំមួយអង្គ ដែលនិមន្តទៅក្រុងសុខោទ័យ តាមការនិមន្តរបស់ព្រះបាទរាមកំហែង តែអ្នកប្រាជ្ញពីនគរស្រីធម្មរាជនេះ អាចទាក់ទងជាមួយអ្នកសុខោទ័យដោយប្រើភាសាខ្មែរឬភាសាមនបាន [(២)] ។ ម្យ៉ាងទៀត នៅក្នុងភូមិភាគខាងត្បូងនេះ គេតែងតែប្រើអក្សរខម គឺអក្សរខ្មែរ មកដល់កាលសម័យមិនសូវជាយូរប៉ុន្មានទេ ។ មនុស្សដែលបានទទួលការអប់រំជំនាន់ជីតារបស់នាងខ្ញុំ (ដាវរឿង វិទ្យារដ្ឋ) ចេះអានអត្ថបទដែលសរសេរជាអក្សរខម [(៣)] ។ ក៏ប៉ុន្តែ នៅតែត្រូវមានការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីឲ្យដឹងថា តើតួអក្សរខមដែលគេប្រើនៅភាគខាងត្បូងនេះ ខុសពីតួអក្សរខមដែលគេប្រើនៅភូមិភាគដទៃទៀតនៃប្រទេសថៃឬទេ?




ផែនទីទី ១ ÷ ឈូងសមុទ្រសៀម




ផែនទីទី ២ ÷ ខេត្តក្នុងភូមិភាគខាងត្បូងនៃប្រទេសថៃ

តាមរឿងនិទានដែលបានផ្សាយពីមាត់មួយទៅមាត់មួយតាំងពីយូរលង់មកហើយ ប្រជាជនថៃបានមកតាំងលំនៅឋាននៅភាគខាងត្បូងនៃប្រទេសថៃកាលពី ព.ស. ១៩២៨ ត្រូវនឹង គ.ស. ១៣៨៥ គឺនៅពេលដែលព្រះបាទរាមេសូរ ព្រះចៅក្រុងស្រីអយុធ្យា បានទ្រង់វាយឈ្នះនគរឈៀងហ្មៃនៅភាគខាងជើង ហើយបានកៀរពស្រ្តទាំងឡាយមកជម្លៀសដល់ភាគខាងត្បូង ដោយបង្ខំគេឲ្យតាំងលំនៅឋាននៅនគរស្រីធម្មរាជនិងនៅខេត្តដទៃទៀតនៅភាគខាងត្បូង ។ ក៏ប៉ុន្តែ តាមប្រសាសន៍របស់លោក ប្រសើដ្ឋ ណៈ នគរ ដែលលោក ពិនិច្ច វណ្ណង៉ាម បាននាំមកថ្លែង រឿងនេះពុំមែនជាការពិតទេ ពីព្រោះមិនបានចារទុកក្នុងពង្សាវតារទាំងឡាយ (ពិនិច្ច វណ្ណង៉ាម ១៩៩២: ៤៤-៤៥) ។ តាមយោបល់មួយទៀតដែលបានអាងលើហេតុការណ៍ខាងភាសាសាស្ត្រ (ប្រោន ១៩៨៥: ២) «[ប្រជាជនក្រុងសុខោទ័យ ជាបុព្វបុរសផ្ទាល់របស់ប្រជាជនថៃនៅភូមិភាគខាងត្បូង]» ។ តាមយោបល់នេះ «[ព្រះបាទរាមកំហែងបានទ្រង់វាយឈ្នះនគរស្រីធម្មរាជ រួចហើយបានបញ្ជូនរេហ៍ពលនិងមន្ត្រីរាជការជាចំនួនធំ ឲ្យមកតាំងលំនៅប្រមូលឈរជើង ។ ប្រជាជនដែលរស់នៅក្នុងតំបន់នេះបានរៀនភាសារបស់មន្ត្រីរាជការទាំងនេះ ដូច្នេះភាសាសុខោទ័យបានសាយភាយ]» ។ ចន្លោះពេលនោះ ភាសារបស់ប្រជាជនក្រុងស្រីអយុធ្យាក៏បានសាយភាយទៅខាងជើងវិញ រួចមកបានជំនួសភាសាសុខោទ័យនៅភាគខាងជើងនៃប្រទេសថៃ ។ តែ តាមភាសាវិទូម្នាក់ទៀត ឈ្មោះ ឌីល្ល័រ «[ក្នុង

ប្រវត្តិសាស្ត្រ មានប្រជាជនដែលនិយាយភាសាថៃ ចំនួនច្រើន ដែលមកតាំងភូមិឋានក្នុងតំបន់ជ្រោយនៃប្រទេសថៃ រយៈពេល ៥ សតវត្សរ៍មុន]» (ឌីល្វ័រ ១៩៨៥: ៣២០) គឺតាំងពីសតវត្សរ៍ទី ១៥ កន្លះ ជាអំឡុងពេល ២ សតវត្សរ៍ក្រោយពេលគេថា ព្រះបាទរាមកំហែងបានទ្រង់វាយឈ្នះនគរស្រីធម្មរាជ ។ តាមលោក វិយើរី (១៩៩១: ៣៤៩-៥០) ភាសាថៃខាងត្បូងក្លាយមកពីភាសាអយុធ្យា ដែលបានផ្សាយមកភូមិភាគខាងត្បូងបន្តិចម្ដង ៗ ហើយប្រហែលបានប្រែប្រួលដោយបានទទួលឥទ្ធិពលពីភាសាដទៃ ដូចជា មន-ខ្មែរ និងមឡាយូ ជាដើម ។

ក្នុងសម័យដើមដំបូង ប្រជាជនភាគច្រើនជាម្ចាស់ភាសាក្នុងអំបូរភាសាមន-ខ្មែរ ។ ក្នុងភូមិភាគខាងត្បូងនៃប្រទេសថៃ នៅសេសសល់ប្រជាជនខ្លះនេះ នៅខេត្តយ៉ះឡា ត្រាំង ស្ទូល និងពទ័លុង ចែកជាក្រុមតូច ៗ ដែលនិយាយគ្រាមភាសាស្រដៀងគ្នា ។ ឧទាហរណ៍ មានក្រុមមួយ ឈ្មោះថា សាកៃ នៅប្រទេសមឡាយូ និង ង៉ោះ នៅប្រទេសថៃ ។ ពាក្យថា ង៉ោះ អានថា /ង៉ោះ/ ក្នុងភាសាសៀម មានន័យថា សាវម៉ាវ បានជាគេហៅជនជាតិង៉ោះយ៉ាងនេះ ដោយសារគេមានសក់កណ្ដាញ់ក្រាប [៤] ។ ជនជាតិនេះហៅខ្លួនឯងថា "ម៉ាន់និ" ឬ "មនិ" មានន័យថា មនុស្ស ។

នៅក្នុងពាក្យស័ព្ទភាសាថៃខាងត្បូង មានឥទ្ធិពលពីភាសាមន តែយើងត្រូវធ្វើការស្រាវជ្រាវតទៅទៀត ដើម្បីឲ្យដឹងថា ឥទ្ធិពលនេះមានចាប់តាំងពីពេលណាមក ។ នៅនគរស្រីធម្មរាជ មានចារឹកចំនួនពីរដែលអ្នកខ្លះបានគិតស្មានថាសរសេរជាភាសាមន តែមានមួយដែលនៅសល់តែបំណែកតូច ៗ គឺចារឹកវត្តមហាធាតុ ក្នុងទីរួមខេត្តនគរស្រីធម្មរាជ (បណ្ណាល័យជាតិ ១៩៨៦: ៣៨-៤១) ហើយមួយទៀតពិបាកអានណាស់ គឺចារឹកវិហារពោធិ៍លង្កា វត្តព្រះមហាធាតុវរមហាវិហារ ក្នុងទីរួមខេត្តនគរស្រីធម្មរាជ (បណ្ណាល័យជាតិ ១៩៨៦: ១១២-១១៨) ។ ភាពជាមននៃចារឹកពីរនេះ នៅតែជារឿងគួរឲ្យសង្ស័យ (ចៅវ័រ ១៩៩២: ៥៣៣) ។ សូម្បីតែមានដំណែលមនតិចណាស់ក៏ដោយ ក៏តាមការស្រាវជ្រាវខាងភាសាសាស្ត្រខ្លះ គេថា ពាក្យសាមញ្ញភាសាថៃខាងត្បូងចំនួនសាមសិបភាគរយ ជាពាក្យភាសាមន (ហេម្ម៉ត័ ១៩៩៤: ១០១) ។

ប្រហែលទំនាក់ទំនងជាមួយប្រជាជនមននេះហើយ ដែលបានជួយផ្សព្វផ្សាយព្រះពុទ្ធសាសនាថេរវាទពីស្រីលង្កា នៅក្នុងនគរស្រីធម្មរាជ ។ ភូមិភាគនេះជាដំណាក់សម្រាប់ការធ្វើដំណើររវាងប្រទេសឥណ្ឌា ចិន និងជ្រោយឥណ្ឌូចិន ។ យើងអាចសន្មតបានថា មានអ្នកដំណើរពីឥណ្ឌាដែលស្ថិតនៅភូមិភាគខាងត្បូងនៃប្រទេសថៃនេះ ជាពិសេសអ្នកដំណើរជាតិទមិឡ ពីព្រោះយើងដឹងថាពួកគេមានគ្រឹះស្ថានជំនួញនៅក្នុងភូមិភាគនេះ ហើយមានចារឹកជាភាសាទមិឡចំនួនពីរ (សេដែស ១៩២៩: ចារឹកលេខ ២៦ និង ២៩, ហ៊ុល្ត្ស ១៩១៣-១៩១៤) ។

នៅភូមិភាគខាងត្បូងនេះ ក៏មានជនជាតិអូស្ត្រូណេស៊ី ដូចជាជនជាតិចរកជនតាមសមុទ្រ (ថៃខាងត្បូងហៅពួកគេថា ឆាវឡេ ១ មានន័យថា អ្នកសមុទ្រ) ហើយទំនងជាមានជនជាតិមឡាយូផងដែរ ។

មានឥទ្ធិពលមួយទៀត គឺឥទ្ធិពលរបស់មហាអំណាចស្រីវិជ័យ ដែលជាអំណាចខាងសមុទ្រមួយមានអត្ថិភាពពី ស.វ. ទី ៧ នៃ គ.ស. ដល់ ស.វ. ទី ១៤ ។ នគរស្រីវិជ័យ មានឥទ្ធិពលនៅភាគខាង

ត្បូងនៃប្រទេសថៃនៅ ស.វ. ទី ៨ ។ យើងដឹងពីរឿងនេះ ដោយសារសិលាចារឹកវត្តសេមាមឿង ក្នុងខេត្តនគរស្រីធម្មរាជ ដែលមានចុះមហាសករាជ ៦៩៧ ត្រូវនឹង គ.ស. ៧៧៥ (សេដែស ១៩៨៩: ៣៣៤-៣៣៥) ។

## ពាក្យខ្មែរក្នុងភាសាថៃខាងត្បូង និង ក្នុងស្ថាននាម

ក្នុងវិស័យភាសាសាស្ត្រនៅប្រទេសថៃ មានស្រទាប់មន-ខ្មែរមួយក្នុងគ្រាមភាសាថៃខាងត្បូង ។ គេអាចឃើញនូវវត្តមានរបស់ស្រទាប់នេះក្នុងគ្រាមភាសាថៃខាងត្បូងទាំងឡាយ និងនៅក្នុងឈ្មោះស្ថាននាម (ឈ្មោះទីកន្លែង) ។ នៅក្នុងនិក្ខេបបទថ្នាក់បណ្ឌិត ដែលលោក ប្រេមិន្ទ្រ គារវី បានការពារកាលពីឆ្នាំ ១៩៩៥ នៅដេប៉ាតឺម៉ង់ភាសាសាស្ត្រនៃសាកលវិទ្យាល័យចុឡាលង្ករណ៍ មានបញ្ជីរាយពាក្យខ្មែរដែលមាននៅក្នុងភាសាថៃខាងត្បូង ចំនួន ១៣២០ ពាក្យ ដែលចំនួនធំមានប្រើតែនៅក្នុងភាសាថៃខាងត្បូងនេះឯង (៥) ។ ពាក្យខ្ចីទាំងនេះ បានចូលក្នុងប្រព័ន្ធសូរស័ព្ទនៃភាសាថៃខាងត្បូងដោយពេញលេញ ហើយន័យវិញក៏ប្រែប្រួលច្រើនដែរ ។ ឧទាហរណ៍ មានពាក្យសាមញ្ញខ្លះដូចតទៅនេះ÷ “និយាយ” ថៃខាងត្បូងថា /លែង/ ក្លាយមកពីពាក្យខ្មែរថា “ថ្លែង” ។ “អកទឹក” ថៃខាងត្បូងថា /មឹក/ ក្លាយមកពីពាក្យខ្មែរថា “ផឹក” ។ “កន្ទះថ្ងៃ” ថៃខាងត្បូងថា /ង៉ាយ/ ក្លាយមកពីពាក្យមន-ខ្មែរថា “ថ្ងៃ” ។ល។ ពាក្យទាំងនេះ ពុំមានទៅក្នុងភាសាសៀម ដែលគេនិយាយនៅភូមិភាគកណ្ដាលទេ ដូច្នេះយើងអាចគិតស្មានបានថា ភាសាថៃខាងត្បូងបានយកពីភាសាខ្មែរផ្ទាល់ គឺពុំបានយកតាមរយៈភាសាសៀមឡើយ ។

ពាក្យខ្មែរ ដែលមានក្នុងស្ថាននាមនៃភូមិភាគខាងត្បូងនេះ មានប្រយោជន៍ពិសេសសម្រាប់ការស្រាវជ្រាវ ដោយហេតុថា ក្នុងករណីជាច្រើន ពាក្យទាំងនេះ លែងជាពាក្យដែលគេប្រើក្នុងភាសាសមញ្ញក្នុងបច្ចុប្បន្ននេះទៀតហើយ ។

យើងអាចដឹងពីកាលសម័យដែលពាក្យទាំងនេះបានជ្រាបចូលក្នុងភាសាថៃខាងត្បូង យ៉ាងជាក់ច្បាស់ក្ដី មិនជាក់ច្បាស់ក្ដី ដោយធ្វើការវិភាគស្រៈនិងព្យញ្ជនៈ ។ ឧទាហរណ៍ មានពាក្យមួយ ដែលគេសរសេរ «ពង» តែបញ្ចេញសម្លេងថា /ផាំង/ មានន័យថា អាងទឹក ជាពាក្យមកពីភាសាខ្មែរបុរាណថា ត្រពាង ឬ ត្រវង (ខ្មែរសព្វថ្ងៃថា ត្រពាំង) ដែលយើងអាចសង្កេតឃើញក្នុងឈ្មោះទីកន្លែងជាច្រើន ដែលមានអាងទឹក ។ បើយើងវិភាគការបញ្ចេញខ្យល់ព្យញ្ជនៈដើមនិងស្រៈ យើងអាចដឹងថា ពាក្យនេះ ថៃខាងត្បូងបានយកពីភាសាខ្មែរមុនសម័យអង្គរបានចប់ទៅ ។

បើយើងសិក្សាអំពីន័យស្ថាននាមទាំងនេះ យើងឃើញថា មានក្នុងវិស័យផ្សេងៗ ពាក្យទាំងនេះសំដៅទៅលើភូមិសាស្ត្រ រុក្ខជាតិ សត្វតិរច្ឆាន និងវប្បធម៌ ។

បើយើងសិក្សាអំពីស្ថានភាពនៃស្ថាននាមទាំងនេះ យើងអាចរកន័យដើមជាភាសាខ្មែរបាន ។ ឧទាហរណ៍ មានស្ទឹងមួយដែលហូរចាក់ទៅក្នុងទន្លេសាបសុងខ្លា មានឈ្មោះថា /ឡាំប៉ាំ/ (ហូរចាក់ទៅត្រង់ភាគដែលគេហៅ ទន្លេហ្លួង មានន័យថា “ទន្លេធំ”) ។ ឈ្មោះនេះ ប្រហែលមកពីពាក្យខ្មែរ

បុរាណថា អំរាំ ពាក្យខ្មែរសព្វថ្ងៃថា រាម (ដាវរឿង វិទ្យារដ្ឋ ១៩៩៩: ២៩) ។ ឧទាហរណ៍មួយទៀត មានពាក្យដែលសរសេរ ទះលេ អានថា /ឡេ/ ជាពាក្យសាមញ្ញ មានន័យថា សមុទ្រ ឬ បឹងទឹកប្រៃក្បែរសមុទ្រ ជាពាក្យក្លាយមកពីខ្មែរថា ទន្លេ ។ តែពាក្យនេះ ក៏ឃើញមានក្នុងឈ្មោះទីកន្លែងដែលមានទឹកសាបដែរ ។ នៅក្នុងករណីនេះ គេយកពាក្យមួយទៀតយកដាក់ផ្សំជាមួយគ្នា ដែលជាពាក្យភាសាថៃ មានន័យស្រដៀងឬប្រហាក់ប្រហែលគ្នានឹងន័យរបស់ពាក្យក្នុងភាសាខ្មែរ ដូចជាពាក្យថា «ហ្នង»[៦] អានថា /ណង/ ដែលមានន័យថា ត្រពាំងក្នុងភាសាថៃ ទៅជា «ហ្នងទះលេ» ។ ឧទាហរណ៍ទាំងនេះសបង្ហាញឲ្យឃើញថា ប្រជាជនដែលនិយាយភាសាខ្មែរ និងប្រជាជនដែលនិយាយភាសាថៃ រស់នៅជិតគ្នា ហើយបានឆ្លងដំណាក់កាលមួយ ជាពេលដែលប្រជាជនទាំងពីរនេះចេះនិយាយទាំងភាសាខ្មែរ ទាំងភាសាថៃ ។

មានស្ថាននាមដែលពាក់ព័ន្ធនឹងជីវភាពក្នុងសង្គម សេដ្ឋកិច្ច និងសាសនា ដែលអាចផ្តល់នូវពត៌មានសំខាន់ៗ អំពីរបៀបដែលភូមិភាគនេះបានទទួលឥទ្ធិពលនិងយកលក្ខណៈជាខ្មែរ ។ នាងខ្ញុំ (ដាវរឿង វិទ្យារដ្ឋ) រកស្ថាននាមចំនួនបួនបាន ក្នុងខេត្តនគរស្រីធម្មរាជនិងសុងខ្លា ដែលពាក់ព័ន្ធទៅនឹងគោរមងាររបស់មន្ត្រី និងការរៀបចំខាងសង្គមនៃប្រទេសកម្ពុជាបុរាណ ។ ស្ថាននាមខ្លះនេះអាចឃើញក្នុងឯកសារមុន ស.វ. ទី ១៩ ដូចតទៅនេះ÷ ជ្ងន ឬ ជ្ងរ ជាឈ្មោះរបស់វត្តមួយ ដែលជាពាក្យមកពីភាសាខ្មែរបុរាណថា ឆ្នោញ (ជាងាររបស់មន្ត្រីនៅសម័យអង្គរ) ។ មានភូមិមួយ សរសេរឈ្មោះជា «កាំលោន» អានថា /ម៉្ងន/ ហើយឈ្មោះនេះមកពីភាសាខ្មែរបុរាណថា កំលោញ (ជាក្រុមនិងងារមួយនៅសម័យមុនអង្គរនិងសម័យអង្គរ) ។ មានវត្តមួយនៅខេត្តនគរស្រីធម្មរាជ ឈ្មោះ «ផរេតង» អានថា /ផ:ដែង/[៧] ។ ពាក្យថា ផរេតងនេះ ក៏សម្រាប់ហៅពួកព្រាហ្មណ៍ ហើយជាពាក្យមកពីភាសាខ្មែរបុរាណថា ម្រតេង ឬ កម្រតេង (ក្នុងភាសាខ្មែរនៅ ស.វ. ទី ១៩ និងទី ២០ ថាកម្តែង) ។ ហើយឈ្មោះមួយទៀត គឺ «រះនោត» (រនោត) ដែលមកពីភាសាខ្មែរបុរាណសរសេរថា ន្ទោច, នោច, ណ្ទោច, ណោច ឬ ណ្តោច ភាសាខ្មែរទំនើបថា រនោច ។ ឈ្មោះនេះ ប្រហែលមានន័យថា ជាភូមិបក្សរនោចដូចក្នុងប្រទេសកម្ពុជាសម័យបុរាណ គឺភូមិដែលអ្នកស្រុកជាប់កំណែនរាល់បក្សរនោច ។

ដោយសារស្ថាននាមទាំងនេះ យើងអាចធ្វើសម្មតិកម្មថា ធ្លាប់មានការរៀបចំខាងសង្គមនិងសាសនានៅភូមិភាគខាងត្បូងនេះ ដែលបានយកគំរូរបស់ចក្រភពខ្មែរបុរាណជាតម្រាប់ ។

## ទិន្នន័យខាងប្រវត្តិសាស្ត្រខ្លះ ដែលអាចពន្យល់បរិបទនៃខ្មែរូបនីយកម្ម

ជ្រោយមឡាយូជាភូមិភាគមួយដែលប្រជាជនដែលនិយាយភាសាក្នុងអំបូរភាសាផ្សេងៗ គ្នា បានលាយឡំគ្នា ។ អំបូរភាសាទាំងនេះ គឺអំបូរភាសាអូស្ត្រូណេស៊ី ១ អំបូរភាសាទ្រាវិឌ ១ អំបូរភាសាឥណ្ឌូ-អឺរ៉ុប ១ អំបូរភាសាមន-ខ្មែរ ១ ។ល។ ការលាយឡំនេះបានកើតឡើងជាពិសេសក្នុងកាលសម័យមួយដែលហៅថា កាលសម័យដែលមានដំណើរការនៃឥណ្ឌាភាវូបនីយកម្ម នៅក្នុងសតវត្សរ៍ដំបូងៗ នៃ

គ្រិស្តសករាជ ។ បូរដីឈ្មោះ គ្រាស ដែលជាភាគចុងភ្លៀតបំផុតនៃជ្រោយមឡាយូ ជាដំណាក់មួយជាទីនិយមរបស់អ្នកធ្វើដំណើរតាមសមុទ្រ ពីឥណ្ឌាដល់ប្រទេសចិន ហើយដែលបានជួយផ្សព្វផ្សាយអារ្យធម៌ឥណ្ឌាទូទាំងជ្រោយឥណ្ឌូចិន ។ រឿងនិទានមួយក្នុងសាវតារចិននិយាយអំពីការរួមសង្វាសរបស់ព្រាហ្មណ៍មួយរូប ជាមួយនឹងធីតារបស់ស្តេចមួយអង្គ ដែលជាដើមកំណើតនៃរាជវង្សហ្វូណន ។ ព្រាហ្មណ៍នេះមកពីប្រទេសឥណ្ឌាតាមរយៈប្រទេសមួយទៀត ដែលប្រហែលជាស្ថិតនៅតាមឆ្នេរសមុទ្រខាងកើតនៃជ្រោយមឡាយូ ។ រឿងក្នុងសាវតារចិននេះ អាចធ្វើឲ្យយើងយល់ឃើញថាទំនាក់ទំនងរវាងឆ្នេរសមុទ្រខាងលិច និងឆ្នេរសមុទ្រខាងកើតនៃឈូងសមុទ្រសៀម មានអាយុកាលជិត ២០០០ ឆ្នាំហើយ ។

នៅក្នុងសម័យក្រោយមក មានអត្ថបទចិនមួយ ដែលថែងអំពីប្រទេស“គៀឡូហ៊ី” ដែលជាប់នឹងព្រំដែនខាងត្បូងនៃចក្រភពរបស់ព្រះបាទ សូរ្យវរ្ម័ន ទី ២ (ពី គ.ស. ១១១៣ ដល់ប្រមាណ គ.ស. ១១៥០) (សេដែស ១៩៨៩: ៣៥) ។ ប្រទេសនេះ ប្រាកដជា «ស្រុកគ្រហិ» ដែលមានថែងឈ្មោះក្នុងចារឹកលើបល្ល័ង្កព្រះពុទ្ធរូបមួយអង្គក្នុងវត្តហួវៀង ខេត្តសុរាស្ត្រធានី ។ ចារឹកនេះមានចុះមហាសករាជ ១១០៥ ត្រូវនឹងគ្រិស្តសករាជ ១១៨៣ (សេដែស ១៩២៩: ៣០ ឌុយប៉ុងត៍ ១៩៤២: ១០៩) ។ ចារឹកនេះផ្តល់ភស្តុតាងដ៏សំខាន់អំពីខ្មែរូបនីយកម្ម (ការទទួលភាសានិងអារ្យធម៌ខ្មែរ) នៃភូមិភាគនេះ ។ សូម្បីតែតួអក្សរលើចារឹកនេះប្លែកពីតួអក្សរដែលមានប្រើនៅភូមិភាគឯទៀតដែលមានសិលាចារឹកជាភាសាខ្មែរក៏ដោយ ក៏ភាសាប្រើគឺជាភាសាខ្មែរដដែល ។ ម្យ៉ាងទៀត នៅក្នុងចារឹកវត្តហួវៀងនេះ មានគោរមងារមួយ ដែលលាយឡំងារសម័យអង្គរនិងងារដែលគេប្រើក្នុងអាណាចក្រស្រីវិជ័យ គឺ «កម្រតេងអញមហារាជ» ។ នៅក្នុងចារឹកនេះ មានងារមួយទៀតដែលគេប្រទះឃើញលើសិលាចារឹកខ្មែរ គឺ «ម្រតេង» ។ ទិន្នន័យនេះ ក៏ជួយបញ្ជាក់ថែមទៀតនូវសម្មតិកម្មដែលយើងខ្ញុំបានធ្វើដោយពឹងផ្អែកទៅលើស្ថាននាម គឺថា ការរៀបចំខាងសង្គមនិងខាងសាសនាធ្វើតាមគំរូខ្មែរ ។

ដូច្នេះ ក្រុមអភិជននៅភូមិភាគខាងត្បូងនេះ ប្រើភាសាខ្មែរនៅសតវត្សរ៍ទី ១២ ហើយស្ថានការណ៍នេះក៏បានបន្តជាច្រើនសតវត្សរ៍មកទៀត ។ យើងមានភស្តុតាងមួយទៀតក្នុងអត្ថបទមួយស្តីពីកល្បនា (វណ្តាប់) ដែលគេថ្វាយចំពោះវត្តអារាម ។ អត្ថបទនេះសរសេរជាភាសាខ្មែរដែលមានពាក្យថៃច្រើនមកលាយឡំគ្នា ហើយមានចុះពុទ្ធសករាជ ២២៤២ ត្រូវនឹង គ.ស. ១៦៦៩ (សំណាក់នាយករដ្ឋមន្ត្រី ១៩៦៧: ១) ។ ការលាយឡំពីរភាសាដូច្នេះ ធ្វើឲ្យសម្មតិកម្មរបស់យើងខ្ញុំកាន់តែរឹងមាំឡើង គឺថា មានជនជាតិទាំងពីរ បានរស់នៅជិតគ្នា ហើយបានឆ្លងដំណាក់កាលមួយ ដែលគេចេះនិយាយទាំងពីរភាសា ។ ម្យ៉ាងទៀត អត្ថបទនេះ ដែលមកពីវត្តខៀននៅបាងកែវ ខេត្តព័ទលុង សរសេរជាតួអក្សរ ដែលក្នុងអត្ថបទនេះ គេឲ្យឈ្មោះថាជា “គាំពុជាក្សរ” (អក្សរកម្ពុជា) ។ ប៉ុន្តែ តួអក្សរនេះប្លែក មិនដូចអក្សរមូល ឬ អក្សរជ្រៀងដែលមានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ។ អក្សរនេះ

*ទំនងជាអក្សរផ្ទាល់ភូមិភាគខាងត្បូងនេះ តែក្នុងសាត្រាដទៃទៀតស្ដីពីព្រះពុទ្ធវចនៈ គេប្រើអក្សរខមដូចនៅភូមិភាគកណ្ដាលនៃប្រទេសថៃ (ប្រទេសសៀម) ដែលស្រដៀងគ្នាណាស់នឹងអក្សរមូលរបស់ខ្មែរ ។*

*តាមទស្សនវិស័យប្រវត្តិសាស្ត្រសិល្បៈ ឥទ្ធិពលនៃសិល្បៈខ្មែរ ឬសិល្បៈបែបខ្មែរ ក៏មាននៅក្នុងភូមិភាគខាងត្បូងនេះដែរ ជាពិសេសបដិមាតូចៗ ដែលតំណាងឲ្យទេវតានិងពោធិសត្វនៃសាសនាមហាយាន និងព្រះពុទ្ធ (ហ្សាក់-ហ៊ែរហ្គ៊ូអាល់ក៍ ១៩៩៦: ៤១១) ។ គេបានប្រទះឃើញដំណែលទាំងនេះ ជាពិសេសក្នុងខេត្តនគរស្រីធម្មរាជ និងក្នុងស្រុកស្ទឹងព្រះ ខេត្តសុងខ្លា ។*

*ការណ៍ដែលមានដើមត្នោតយ៉ាងសម្បូរក្នុងស្រុកស្ទឹងព្រះ ប្រហែលវាក៏ជាកស្តុតាងថា ធ្លាប់មានវត្តមានរបស់ជនជាតិខ្មែរក្នុងសម័យបុរាណ ពីព្រោះមានអ្នកខ្លះចូលចិត្តគិតថា តំបន់ដែលសម្បូរដើមត្នោតក្នុងប្រទេសថៃនិងយួនសព្វថ្ងៃនេះ ច្រើនមានន័យថា ធ្លាប់មានប្រជាជនខ្មែររស់នៅ ឬ នៅតែមានភូមិខ្មែរនៅក្នុងតំបន់ទាំងនេះ ។ តែការដាំដើមត្នោត មុខជាមកពីភូមិភាគខាងត្បូងនៃប្រទេសឥណ្ឌា (ដែលវែរត៍ ១៩៦១: ២៨៩) ហើយនៅឯនោះ ក៏ដូចនៅប្រទេសភូមាដែរ ដើមត្នោតសម្បូរណាស់ (៨) ។*

*មួយវិញទៀត បើយើងប្រៀបធៀបពិធីបុណ្យនិងសិល្បៈរបស់ថៃខាងត្បូងនិងខ្មែរខ្លះ យើងសង្កេតឃើញថា ជួនកាលមានភាពស្រដៀងគ្នាណាស់ ដែលនាំឲ្យគិតថា ធ្លាប់មានទំនាក់ទំនងតាំងពីបរមបុរាណមក ។ ឧទាហរណ៍ បុណ្យធំជាងគេនៅភូមិភាគខាងត្បូងនៃប្រទេសថៃ គឺប្រព្រឹត្តឡើងនៅខែភទ្របទ ហៅថា /ប៊ុនដឿនសិប/ គឺ "បុណ្យខែ ១០" (ខែ ១០ គឺខែភទ្របទ) ត្រូវនឹងបុណ្យកាន់បិណ្ឌរបស់ខ្មែរ ហើយបុណ្យនៅថ្ងៃ ១៥ រោចខែភទ្របទ ហៅថា /ឈិងប្រេត/ មានន័យថា "ដែង, ដណ្ដើម ឬ ចាប់យកប្រេត" (ហេម្មៃត៍ ១៩៩៤: ១១៦-១១៨) ត្រូវនឹងថ្ងៃភ្ជុំបិណ្ឌរបស់ខ្មែរ ។ សៀម (ថៃកណ្ដាល) ហៅបុណ្យកាន់បិណ្ឌថា /ប៊ុនសាត/ "បុណ្យសារទៈ" រីឯលាវហៅ /ប៊ុនហខៅសាក/ ឬ /ប៊ុនហខៅសៈឡាក/ "បុណ្យខ្ចប់បាយស្លាក" តែសម្រាប់សៀមនិងលាវ បុណ្យនេះគ្មានសារៈសំខាន់ និង ភាពឱឡារិកដូចនៅប្រទេសខ្មែរឬភូមិភាគខាងត្បូងនៃប្រទេសថៃទេ ។ រឿងគួរឲ្យឆ្ងល់មួយ គឺថា ចំពោះថៃខាងត្បូង សង្ក្រាន្ត (ពិធីចូលឆ្នាំ) មិនមានសភាពឱឡារិកអធិកអធមឡើយ ។ នេះ ផ្ទុយពីរបៀបដែលខ្មែរ សៀម លាវ មន និង ភូមា ធ្វើពិធីបុណ្យចូលឆ្នាំ ។*

*ឧទាហរណ៍មួយទៀត ថៃខាងត្បូងមានល្ខោនមួយយ៉ាងហៅ ហ្នង័ត:លុង ដែលមានប្រជាប្រិយ-ភាពសម្បើមតាំងពីយូរលង់មកហើយ សព្វថ្ងៃនេះ អ្នកស្រុកក៏និយមមើលច្រើនជាងមើលកម្មវិធីទូរទស្សន៍ (ហេម្មៃត៍ ១៩៩៤: ១២១-២២) ។ ហ្នង័ត:លុងនេះ មានលេងតែក្នុងភូមិភាគខាងត្បូងឡើងដល់ខេត្តពេជ្របុរី ហើយមិនមែនជាទីនិយមរបស់មហាជននៅក្នុងភូមិភាគដទៃទៀតនៃប្រទេសថៃឡើយ ។ នៅប្រទេសមឡាយូ គេហៅល្ខោននេះថា វ៉ាយ៉ាំងគុលិតហ្គឹដិក (៩) ។ នៅប្រទេសខ្មែរមានស្បែកតូច ដែលស្រដៀងគ្នានឹងហ្នង័ត:លុងណាស់ តែមិនដូចគ្នាទាំងស្រុងនោះទេ (១០) ។ ម្យ៉ាងទៀត តាមការនិយាយទៅតាមទម្លាប់ស្រុក ខ្មែរក៏ហៅស្បែកតូចថា អាយ៉ង, ណាំងតាលុង ឬ ណាំងកាលុង ផងដែរ (សូមមើលលោក ម៉ារស្ដាល ១៩៥៨, និង លោក ពេជ្រ ទុំក្រវិល [២០០០]:*

៣៧) ។ ពាក្យថា អាយ៉ង ប្រហែលជាក្លាយមកពីពាក្យមឡាយូ និង ជ្វា ថា វ៉ាយ៉ាំង ហើយប្រហែលជាពាក្យនេះ ក៏ក្លាយមកពីពាក្យថា បាយ៉ាំង មានន័យថា ស្រមោល[១១] ។ រីឯពាក្យថា ណាំង មានន័យថា ស្បែក ក្នុងបណ្ដាភាសាថៃទាំងឡាយ តែគេពុំស្គាល់ន័យដើមនៃពាក្យថា តៈលុង យ៉ាងជាក់លាក់នោះទេ ។ ឈ្មោះទាំងនេះ គួរឲ្យចាប់អារម្មណ៍ណាស់ ដោយសបង្ហាញឲ្យឃើញថា ឥទ្ធិពលវប្បធម៌ មានទាំងសងខាង គឺពុំមែនតែពីប្រទេសកម្ពុជាមកបួរដីក្រាស តែក៏មានពីបួរដីក្រាសទៅប្រទេសកម្ពុជាវិញផងដែរ ។ ឈ្មោះណាំងតាលុង ឬ ណាំងកាលុង ជាពាក្យថៃ ហើយយើងដឹងថាពាក្យថៃបានចូលភាសាខ្មែរក្រោយសម័យអង្គរហូតដល់ចុងគ្រិស្តសតវត្សរ៍ទី ១៩[១២] ។ យើងអាចធ្វើសម្មតិកម្មបានថា ខ្មែរច្បាស់យកសិល្បៈស្បែកតូចពីថៃខាងត្បូង ឬ មឡាយូតែម្ដង គឺពុំបានយកតាមរយៈសៀមសម័យក្រុងសុខោទ័យ ក្រុងស្រីអយុធ្យា ឬ បាងកកទេ[១៣] ។ ពួកមឡាយូ ដែលបានតាំងសហគមន៍តូចៗ នៅប្រទេសខ្មែរ ហើយដែលខ្មែរហៅពួកគេថា ជ្វាៗ ជាអ្នកដើរសមុទ្រដ៏ប៉ិនប្រសប់ ហើយមានទំនាក់ទំនងនឹងប្រទេសខ្មែរតាំងពីបរមបុរាណមកម្ល៉េះ ។ ម្យ៉ាងទៀត ពី ស.វ. ទី ១៤ ដល់ ស.វ. ទី ១៧ ប្រទេសកម្ពុជា បានបែរទៅរកប្រទេសដទៃទៀតនិងធ្វើជំនួញតាមផ្លូវសមុទ្រ (វិឃើរី ២០០៤: ៥០-៥១) ។ ដូច្នេះ ខ្មែរទំនងជាបានយក ឬ យកមកវិញនូវសិល្បៈណាំងតាលុង ក្នុងសម័យកណ្ដាល ។

ឧទាហរណ៍ចុងក្រោយ ដល់ពាក់កណ្ដាលទី ១ នៃសតវត្សរ៍ទី ២០ ថៃខាងត្បូងមិននិយមដុតខ្មោចរបស់មនុស្សស្លាប់ភ្លាម ។ បើជាខ្មោចរបស់មនុស្សតែហោង គេនិយមរុំខ្មោចនោះនឹងកន្ទេលយកទៅដាក់ក្នុងគ្រោងឫស្សី រួចយកទៅព្យួរចោលចន្លោះដើមឈើពីរដើម ឬ ចន្លោះមែកឈើពីរ ។ ឪពុកនាងខ្ញុំ (ដាវរឿង វិទ្យារដ្ឋ) ធ្លាប់ប្រទះឃើញសពដែលគេព្យួរដូច្នេះកាលនៅពីតូច ។ ដល់កាលណាសពរលួយហើយ ធ្លាក់ឆ្អឹងឆ្អែងដល់ដី អ្នកស្រុកក៏រើសយកទៅព្យួរវិញ មានតែព្រះសង្ឃ ដែលដើរទៅរើសឆ្អឹងនៅលើដីក្នុងព្រៃនោះ យកទៅដុតតាមប្រពៃណីព្រះពុទ្ធសាសនាវិញ (ហេម្ម៉ើត៍ ១៩៩៤: ១១៦) ។ តាមអ្នកស្រី ហេម្ម៉ើត៍ (១៩៩៤: ១១៦) ក្នុងខេត្តបត្តនី សូម្បីតែសពរបស់មនុស្សដែលស្លាប់ដោយអាយុក្ខ័យក៏ដោយ គេក៏ធ្លាប់យកទៅព្យួរចោលក្នុងព្រៃដែរ ។ ប្រហែល នេះត្រូវនឹងកំណត់ហេតុរបស់លោក ជីវ តាក្វាន់ ដែលបានរាយការណ៍ថា ក្នុងគ្រិស្តសតវតស្សរ៍ទី ១៣ នៅប្រទេសកម្ពុជា «មនុស្សស្លាប់ គេឥតមានដាក់ក្ដារមឈូសទេ គេយកតែកន្ទេលក្រាលពីក្រោម យកកំណាត់សំពត់គ្របពីលើ ហើយគេយកទៅព្រៃហើយ [...] លុះសែងទៅដល់ក្រៅក្រុងដល់កន្លែងណាស្ងាត់ គេក៏ដាក់ចោលខ្មោចនោះហើយត្រឡប់មកវិញ» (លី ធាមតេង ១៩៧៣: ៤៥) ។ សព្វថ្ងៃនេះ នៅស្រុកខ្មែរ នៅតាមស្រុកស្រែ គេនៅតែនិយមទៅកប់ខ្មោចឆៅ (ខ្មោចតែហោង) ក្នុងព្រៃសំសាន (ស្មសាន) ឋានស្ងាត់ ។ នៅតំបន់ខ្លះខ្មែរក៏និយមធ្វើបុណ្យលើកខ្មោចស្រោចឆ្អឹងដែរ ហើយនៅភាគខាងត្បូងនៃប្រទេសថៃ ខ្មោចដែលគេមិនព្យួរ គេក៏ធ្លាប់យកទៅកប់មុននឹងធ្វើឈាបនកិច្ច រហូតដល់ ស.វ. ទី ២០ ផងដែរ[១៤] (ហេម្ម៉ើត៍ ១៩៩២: ២៦១) ។ ជនជាតិក្នុងអំបូរមឡាយូ-ប៉ូលីណេស៊ី ក៏មានទម្លាប់កប់ខ្មោចពីរដងដែរ ។

នៅពេលនេះ យើងខ្ញុំពុំអាចជម្រាបបានថា តើដំណើរខ្មែរូបនីយកម្មក្នុងភាគខាងត្បូងនៃប្រទេសថៃនេះ ជាពិសេសនគរស្រីធម្មរាជ មកពីទំនាក់ទំនងផ្ទាល់ជាមួយមជ្ឈមណ្ឌលអំណាចរបស់ចក្រភពខ្មែរបុរាណ ឬអាចមកពីទំនាក់ទំនងជាមួយនគរលពបុរី ដែលជានគរមួយមានលក្ខណៈបែបខ្មែរខ្លាំងណាស់ ដូចដែលមានចែងក្នុងពង្សាវតារនគរឈៀងហ្មៃ (នៅភាគខាងជើងនៃប្រទេសថៃ) ដែលគេបានតែងជាភាសាបាលី (សេដែស ១៩៨៩: ២៤៨-២៥២) ។ យើងខ្ញុំក៏មិនដឹងថា តើមានឯកសារប្រវត្តិសាស្ត្រនៅប្រទេសកម្ពុជា ដែលសម្គាល់ឬនិយាយពីភូមិភាគខាងត្បូងនៃប្រទេសថៃនេះ ។

ពេលនេះ បើពឹងផ្អែកលើពាក្យខ្ចីនិងស្ថាននាម យើងខ្ញុំមានយោបល់ថា ខ្មែរូបនីយកម្មក្នុងវិស័យភាសាសាស្ត្រ បានជ្រាបចូលទាំងពួកវរជន ទាំងប្រជារាស្ត្រតូចតាច ។ ហេតុអ្វីបានជាភាសាខ្មែរអាចផ្សាយយ៉ាងងាយស្រួលដូច្នេះ? យើងដឹងថា ជនជាតិមនិ (ឬ ម៉ាន់និ) ដែលនិយាយភាសាមួយក្នុងអំបូរភាសាមន-ខ្មែរ ហើយដែលនៅសេសសល់តែមួយចំនួនតូចនាពេលសព្វថ្ងៃនេះ បានរស់នៅក្នុងភូមិភាគនេះតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម៉្លេះ ។ ប្រហែលជាវត្តមានរបស់ជនជាតិនេះ ជាកត្តាមួយដែលបានជួយឲ្យដំណើរការនៃខ្មែរូបនីយកម្មបានកើតឡើង ។ ប្រហែលជាមានសហគមន៍ខ្មែរតូច ៗ បានមកតាំងលំនៅនៅភាគខាងត្បូងនៃប្រទេសថៃ ចាប់តាំងពីពេលដំបូងនៃប្រវត្តិសាស្ត្រដោយបានមកពីហ្វូណន ។ តាមអ្នកប្រាជ្ញខ្លះ ហ្វូណនប្រហែលជាពុំមែនជាប្រទេសមានឯកភាពទេ តែមានរដ្ឋតូច ៗ ដែលអ្នកប្រាជ្ញក្នុង ស.វ. ទី ២០ បានប្រមូលផ្តុំគ្នាក្រោមឈ្មោះថា ហ្វូណន ៗ (ធាន់ឌ្វរ័ ២០០០: ១៥) ។ គេគិតស្មានថា តំបន់ហ្វូណន ដែលប្រកបដំនួញតាមផ្លូវសមុទ្រ មានទីតាំងនៅដែនដីសណ្តនៃទន្លេមេគង្គ និងនៅតាមឆ្នេរសមុទ្រខាងត្បូងនៃប្រទេសកម្ពុជានិងវៀតណាមបច្ចុប្បន្ន ។ យើងក៏អាចស្មានបានថា ប្រជាជនក្នុងតំបន់នោះ និយាយភាសាខ្មែរ ។ ដូច្នេះ ប្រហែលជាខ្មែរ ដែលមិនមានឥទ្ធិពលតែនៅលើជ្រលងទន្លេចៅព្រះយ៉ា (ភូមិភាគកណ្តាលនៃប្រទេសថៃ) ក៏មានឥទ្ធិពលនៅភាគខាងត្បូងនៃប្រទេសថៃ ក្នុងអំឡុងពេលជាងមួយសហស្សវត្សរ៍កន្លះយ៉ាងហោចណាស់ ។

នៅក្នុងអត្ថបទនេះ បំណងរបស់យើងខ្ញុំ គឺលើកយកមកនូវបញ្ហាថ្មីៗ ដែលអាចជួយវិស័យសិក្សាស្រាវជ្រាវខ្មែរ-ថៃ ឲ្យលូតលាស់ ។ យើងខ្ញុំមានយោបល់ថា ក្នុងអនាគតកាល គួរតែភ្ជាប់ទាក់ទងការស្រាវជ្រាវដែលគេធ្វើឡើងនៅប្រទេសថៃនិងកម្ពុជា អំពីឥទ្ធិពលខ្មែរនៅជ្រោយមឡាយូ ជាមួយនឹងការស្រាវជ្រាវដែលគេបានធ្វើឡើងនៅប្រទេសមឡាយូអំពីស្រទាប់មន-ខ្មែរ ។ ម្យ៉ាងទៀត ក៏ត្រូវតែធ្វើការប្រៀបធៀបអារ្យធម៌មន-ខ្មែរជាមួយនឹងអារ្យធម៌អូស្ត្រូណេស៊ីផងដែរ ៕

## កំណត់អត្ថន័យ

៉ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះបណ្ឌិត អេម្មានុយអែល ហ្គីយ៉ុង ដែលបានផ្តល់ពត៌មានអំពីអារ្យធម៌មន, បណ្ឌិត គ្រីស្ទាន បៅវ័រ ដែលបានផ្តល់ពត៌មាននិងយោបល់អំពីពួកជនជាតិដើមនានានៅភាគខាងត្បូងនៃប្រទេសថៃ និង នៅប្រទេសមឡាយូ, លោក អេរិក ប៊ូដូំណ្ណ ដែលបានផ្តល់យោបល់អំពីទំនាក់ទំនងរវាងប្រទេសហ្វូណននិងបួរដីក្រាស, និងចំពោះលោក រ៉ូបឺត ហ្វោឡឺរ អំពីល្ខោនស្បែក ។

(១) តាំងពីទសវត្សឆ្នាំ ១៩៨០ មក មានសង្គ្រាមប៉ាកកាបានផ្ទុះឡើងរវាងអ្នកប្រាជ្ញដែលថា ជាសិលាចារឹកពិតប្រាកដ និងអ្នកប្រាជ្ញដែលថា ជាសិលាចារឹកក្លែងក្លាយ ។ មានអ្នកខ្លះដែលមានការសង្ស័យចំពោះអត្ថិភាពនៃព្រះរាជាអង្គនេះ ។ សូមមើលលោក ឆាំប៊ឺរឡែន (១៩៩១) ។ ពង្សាវតារនគរស្រីធម្មរាជបានតំណាលថា មានស្ដេច ១ អង្គបានយាងមកគ្រប់គ្រងនគរស្រីធម្មរាជក្នុង គ.ស. ១២៧៤ មានព្រះនាម ពញាស្រីសៃយណរង្គ ។ ប្រវត្តិវិទូខ្លះបានយល់ថា ជាពញារួង ឬ ព្រះបាទរាមកំហែង តែប្រវត្តិវិទូខ្លះទៀតបានបដិសេធនូវមតិនេះ ។ សូមមើលលោក វិឃើរី (១៩៩១: ៣៨៤) ។

(២) ប៉ុន្តែ តាមយោបល់របស់លោក វិឃើរី (១៩៩១: ៣៣) ដែលជឿថា សិលាចារឹករាមកំហែង ជាសិលាចារឹកក្លែងក្លាយ នៅមហាសករាជ ១២០៧ ជាឆ្នាំដែលមានចុះក្នុងសិលាចារឹកនេះ (ត្រូវនឹង គ.ស. ១២៨៥) នគរស្រីធម្មរាជ ពុំមែនជាមជ្ឈមណ្ឌលសំខាន់នៃពុទ្ធសាសនាបែបសិង្ហល (លង្កា) ទេ ។

(៣) ព្រះសង្ឃ អាចារ្យ ហោរ និងប្រុសៗ ដែលបានទទួលការអប់រំតាមប្រពៃណីក្នុងវត្ត នៅតែចេះអានសាត្រាដែលសរសេរជាអក្សរខម តែចំនួនមនុស្សដែលអានតួអក្សរខមដាច់ ចេះតែធ្លាក់ចុះ ហើយសមត្ថភាពក្នុងការអានយ៉ាងល្អក៏ធ្លាក់ចុះជាលំដាប់លំដោយផងដែរ ដោយហេតុថា តាំងពីរជ្ជកាលនៃព្រះរាមទី ៥ (គ.ស. ១៨៦៨-១៩១០) ការអប់រំ ធ្វើក្នុងសាលារៀនសាធារណៈទូទាំងប្រទេសថៃ ។ សូមមើលអ្នកស្រី អ៊ិងអរ បទមតិត្ត (១៩៩៩) ផងដែរ ។

(៤) ផ្ទៃសាវម៉ាវ គ្រាមភាសាថៃខាងត្បូងហៅ "ហោះៗ" ហើយគេក៏ហៅជនជាតិនោះថា "ហោះៗ" ដែរ ។

(៥) លោក ប្រេមិន្ទ្រ បានធ្វើការស្រាវជ្រាវអំពីគ្រាមភាសាខេត្តសុងខ្លា ។

(៦) ក្នុងអក្សរខមនៅប្រទេសថៃ សញ្ញា "្ច" នេះ មិនមែនជើង ច ទេ ហើយសម្រាប់កត់ស្រះកប់ខ្យល់ អ ។

(៧) ស្រៈនិស្ស័យ "ែ" សៀមសរសេរ "េេ" ។

(៨) តាមយើងខ្ញុំដឹង នៅប្រទេសមឡាយូ គេក៏ច្រើនដាំតាលព្រឹក្សសម្រាប់ធ្វើស្ករដែរ ។ តែដើមឈើនេះ ដែលសម្បូរណាស់ គឺជាប្រភេទផ្សេងពីដើមត្នោតដែលសម្បូរនៅប្រទេសខ្មែរនិងនៅស្ទឹងព្រះ ។ មានប្រភេទ ១ ដែលដុះនៅមឡាយូនិងឥណ្ឌា ដែលខ្មែរហៅ ដើមទន្សែ ។ ប្រភេទ ១ ទៀត សម្បូរណាស់នៅប្រទេសមឡាយូ គេដាំសម្រាប់ធ្វើស្ករ ខ្មែរហៅ ដើមជក់, ដើមដូងព្រៃ ឬ ត្នោតជ្រៃ ។ សូមមើលអ្នកស្រី ឌី ផុន (២០០០: ៤៩, ៩៩, ១៣៦) ។

(៩) តាមអ្នកប្រាជ្ញខ្លះ វ៉ាយ៉ាំងគុលិតហ្គីដិកមកពីភាគខាងត្បូងនៃប្រទេសថៃ តែតាមអ្នកប្រាជ្ញខ្លះទៀត គឺហ្ន័ងតៈលុងដែលមកពីមឡាយូវិញទេ (គួឡាំ-សារ៉ាវ យូសុហ្វ ១៩៩៤: ២៨២) ។

(១០) យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោក រ៉ូប៊ឺត ហ្វាឡឺរ ជាអ្នកឯកទេសខាងហ្ន័ងស្បែក ដែលបានបញ្ជាក់ថា ហ្ន័ងតៈលុង និង ស្បែកតូច ស្រដៀងគ្នាណាស់ តែមិនដូចគ្នាទាំងស្រុងទេ ។

(១១) យើងខ្ញុំសូមថ្លែងអំណរគុណចំពោះកញ្ញា ប៉ាស្កាលីន ទ្រឹក ជាអ្នកឯកទេសខាងភាសាឥណ្ឌូណេស៊ី ដែលបានផ្ដល់យោបល់អំពីន័យរបស់ពាក្យនេះ ។

(១២) នៅចុងសម័យអង្គរ មានពាក្យសៀមខ្លះបានជ្រាបចូលភាសាខ្មែរ ដូចជា «ចៅកូវ» សៀមអានថា /ចៅគូ/ មានន័យថា ម្ចាស់អញ ជាពាក្យសម្រាប់ហៅព្រះសង្ឃ ។ តែនៅសម័យនោះ មានពាក្យសៀមតិចណាស់ក្នុងភាសាខ្មែរ ។

(១៣) ប៉ុន្តែ តាមលោក ពេជ្រ ទុំក្រវិល ([២០០០]: ៣៧-៣៨) ប្រហែលជា «ពាក្យណាំ[ង]តាលុងនេះត្រូវប្រជារាស្ត្រខ្មែរហៅតាមភាសាសៀមក្រោយពីពេលដែលខ្មែរចុះខ្សោយ ហើយត្រូវទទួលយកមរតកកេរ្តិ៍ដំណែល

*ដូនតាខ្លួនដែលសៀមបានរឹបអូសយកទៅក្នុងសម័យសៀមលុកលុយក្រុងអង្គរ [...] និង សម័យបែកលង្វែក [...] ត្រឡប់មកវិញ ។ ប៉ុន្តែ ខ្មែរខ្លះហៅថា ណាំ[ង]កាលុងទៅវិញ ។»*

*(១៤) តាមឯកសារចិន នៅគ្រិស្តសតវត្សរ៍ទី ៣ ក្នុងអាណាចក្រតៈណាវស្រី (តេណាសេរិម) ដែលគេស្មានថាប្រជាជននិយាយភាសាមន គេធ្លាប់ចោលសាកសពមនុស្សឲ្យសត្វត្មាតស៊ី ។ បើត្មាតមិនស៊ីទេ គេគិតថា សពនេះអសោចិ៍ ត្រូវដុតចោលវិញ (គឺជាពត៌មានដែលបណ្ឌិត ហ្គីយ៉ុង បានផ្តល់មកយើងខ្ញុំ ។ សូមមើលលោក វិទ្វេយ៍ ១៩៦៥: ១៧-១៨ ដែរ) ។ ទំនៀមទម្លាប់នេះដូចទំនៀមទម្លាប់របស់អ្នកស្រុកចេនឡា (សូមមើលលោក លី ផាមតេង ១៩៧៣: ៤៥) ៕*

## គន្ថនិទ្ទេសសង្ខេប


⊙ *កេនីយ៍, ចឺរី* (Gainey, Jerry) *និង ធីរព័ន្ធ ល. ថងខាំ* **គូ់ម្វឹ៎ផេនទី៎ភាសាថៃប្រះទេតថៃយ្យ [សៀវភៅណែនាំផែនទីភាសាក្នុងប្រទេសថៃ]** *(ជាភាសាសៀមនិងអង់គ្លេស) បាងកក, គ្រោងការស្រាវជ្រាវភាសាថៃនិងភាសារបស់អ្នកស្រុកទាំងឡាយ, ស្ថាប័នមជ្ឈិមភាសាអង់គ្លេស, ការិយាល័យសាកលវិទ្យាល័យ, ព.ស. ២៥២០ គ.ស. ១៩៧៧ ។*

⊙ *គូឡាំ-សារវ៉ារ យូសុហ្វ* **[វចនានុក្រមល្ខោនបុរាណនៅអាស៊ីអាគ្នេយ៍]** *(ជាភាសាអង់គ្លេស) គូឡាឡាំពួរ, រោងពុម្ពសាកលវិទ្យាល័យអុកស្វហ្វដ៍, ឆ្នាំ ១៩៩៤ ។*

Ghulam-Sarwar Yousof, *Dictionary of Traditional South-East Asian Theatre*, Kuala Lumpur, Oxford University Press, 1994.

⊙ *ឆាន់ឌ្ល័រ, ដេវិឌ* **[ប្រវត្តិសាស្ត្រប្រទេសកម្ពុជា]** *(ជាភាសាអង់គ្លេស) ប៊ោលឌ័រ (រដ្ឋកូឡូរ៉ាដូ), វ៉េស្តវិវប្រេស្ស, ការបោះពុម្ពលើកទី ៣, ឆ្នាំ ២០០០ ។*

Chandler, David, *A History of Cambodia*, Boulder (Colorado), Westview Press, 3rd edition, 2000.

⊙ *ឆាំប៊ឺរឡែន, ហ្សែមស៍ រ. (បណ្ណាធិការ)* **[ការជជែកតវ៉ាគ្នាអំពីសិលាចារឹកព្រះបាទរាមកំហែង ។ អត្ថបទប្រមូល]** *(ជាភាសាអង់គ្លេស) បាងកក, ស្យាមសមាគម, ឆ្នាំ ១៩៩១ ។*

Chamberlain, James R. (Editor), *The Ram Khamhaeng Controversy. Collected Papers*, Bangkok, Siam Society, 1991.

⊙ *ដាវរឿង វិទ្យារដ្ឋ* **[ស្ថាននាមក្នុងឧបទ្វីបភាគខាងត្បូងនៃប្រទេសថៃ ដែលមានដើមកំណើតជាភាសាខ្មែរ]** *(ជាភាសាបារាំង) ប៉ារីស, វិទ្យាស្ថានជាតិនៃភាសានិងអារ្យធម៌នៃបូព៌ាប្រទេស, សារណាបរិញ្ញាបត្រ (មិនបានបោះពុម្ពផ្សាយ), ឆ្នាំ ១៩៩៩ ។*

Daoruang Wittayarat, *Les Toponymes d'origine khmère en Thaïlande péninsulaire*, Paris, INALCO, mémoire de maîtrise (manuscrit), 1999.

⊙ *ដាវរឿង វិទ្យារដ្ឋ* **[ចំណែកទានដល់ការសិក្សាអំពីស្ថាននាមដែលមកពីភាសាមន_ខ្មែរទាំងឡាយក្នុងឧបទ្វីបភាគខាងត្បូងនៃប្រទេសថៃ]** *(ជាភាសាបារាំង) ប៉ារីស, វិទ្យាស្ថានជាតិនៃភាសានិងអារ្យធម៌នៃបូព៌ាប្រទេស, សារណាថ្នាក់អនុបណ្ឌិត (មិនបានបោះពុម្ពផ្សាយ), ឆ្នាំ ២០០០ ។*

Daoruang Wittayarat, *Contribution à une étude des toponymes issus des langues môn-khmer en Thaïlande péninsulaire*, Paris, INALCO, mémoire de D.E.A. (manuscrit), 2000.

⊙ *ដែលវែរត៍, ហ្សង់* **[រូបក័ស្រែចម្ការខ្មែរ]** *(ជាភាសាបារាំង) ប៉ារីស, មូតុង និងក្រុម, ឆ្នាំ ១៩៦១ ។*

Delvert, Jean, *Le paysan cambodgien*, Paris, Mouton & Co., 1961.

◎ ឌី ផុន **វចនានុក្រមរុក្ខជាតិប្រើប្រាស់ក្នុងប្រទេសកម្ពុជា** ភ្នំពេញ ឆ្នាំ ២០០០ ។

◎ ឌីល្ល័រ, អាន់ថោនី « [សម្លេងឡើងចុះ និង ស្រៈ ក្នុងភាសាថៃខាងត្បូង ៖ ភាពមិនសមហេតុផលខាងកាលវិវត្តន៍] » (ជាភាសាអង់គ្លេស) ក្នុង [**ភាសាសាស្ត្រអាស៊ីអាគ្នេយ៍ ៗ ការសិក្សាជូនចំពោះលោក អង់ដ្រេ ហ្ស. ហូឌ្រីគួរត៍**] បាងកក, សាកលវិទ្យាល័យមហិតល, សុរិយា រតនកុល, ដេវិឌ ថូម៉ាស់, សុវិល័យ ប្រេមស្រីរត្ន (បណ្ណាធិការ), ឆ្នាំ ១៩៨៥, ទំព័រ ៣១០-៣៥៤ ។

Diller, Anthony, "Tones and vowels in Southern Thai: a diachronic anomaly", in *Southeast Asian Linguistics, Studies presented to André G. Haudricourt*, Bangkok, Mahidol University, Suriya Ratanakul, David Thomas, Suwilai Premsrirat (eds.), 1985, pp. 310-354.

◎ ឌីហ្វឡុថ, ហ្សេរ៉ារដ៍ « [បណ្ដាភាសាមន-ខ្មែរនៅប្រទេសមឡាយូ, ការចាត់ថ្នាក់និងការបញ្ចូលរបៀបថ្មី] » (ជាភាសាបារាំង) ក្នុង [**អាស៊ីអាគ្នេយ៍និងប្រជុំកោះអាស៊ីអាគ្នេយ៍**] លេខ ៦ (៤), ឆ្នាំ ១៩៧៥, ទំព័រ ១-១៩ ។

Diffloth, G., « Les langues môn-khmer de Malaisie, classification et innovations », *ASEMI*, VI, 4, 1975, pp. 1-19.

◎ ឌុយប៉ុងត៍, ពីយែរ « [ព្រះពុទ្ធស្រុកគ្រហិ និងរចនាបថជៃយា] » (ជាភាសាបារាំង) ក្នុង [**ព្រឹត្តិប័ត្រនៃសាលាបារាំងសែសចុងបូព៌ាប្រទេស**] លេខ ៤២, ឆ្នាំ ១៩៤២, ទំព័រ ១០៥-១១៣ ។

Dupont, Pierre, « Le Buddha de Grahi et l'École de C'aiya », *BEFEO*, XLII, 1942, pp. 105-113.

◎ បណ្ណាល័យជាតិ **ចារឹកនៃប្រះទេតថៃយ ល៉េម ២ អ័ក្សរប័ល្លវៈ អ័ក្សរមុញ ពុទ្ធសតវរទី ១២-២១** [**ចារឹកក្នុងប្រទេសថៃ ក្បាលទី ១ អក្សរបល្លវៈ អក្សរមន ពុទ្ធសតវត្សទី ១២-២១**] (ជាភាសាសៀម) បាងកក, បណ្ណាល័យជាតិ ផ្នែកសិល្បាករ ព.ស. ២៥២៩ គ.ស. ១៩៨៦ ។

◎ បៅវ័រ, គ្រីស្ទាន « [ទំនាក់ទំនងរវាងជនជាតិមន និង អាស៊្លី] » (ជាភាសាអង់គ្លេស) ក្នុង [**ព្រឹត្តិប័ត្រនៃសាលាសិក្សាបូព៌ាប្រទេសនិងអាហ្វ្រិក**] លេខ ៥៥ (៣), ឆ្នាំ ១៩៩២, ទំព័រ ៥៣២-៥៣៧ ។

Bauer, Christian, "Mon-Aslian contacts", *Bulletin of the School of Oriental and African Studies*, Vol. 55 (3), 1992, pp. 532-537.

◎ ប្រទុម ជុំផិងព័ណ្ណ **បោរាណវ័ត្ថុស្ថាននៃភាគតៃ៎ត្វនណ្ហឿរមចេ៊តចង្ហ្វ័ត** [**បុរាណវត្ថុស្ថានក្នុងខេត្ត ៧ នៅភាគខាងជើងនៃភូមិភាគខាងត្បូង**] (ជាភាសាសៀម) បាងកក, ផ្នែកសិល្បាករ, ព.ស. ២៥១៧ គ.ស. ១៩៧៤ ។

◎ ប្រីដា នុនសុខ **ហ្ល័កឋានទាងបោរាណគឌីនៃភាគតៃ៎ធីគៀ្យវក័បអាណាចក្រគ្រីវិជ័យ** [**ភស្តុតាងបុរាណវិទ្យាក្នុងភូមិភាគខាងត្បូង ដែលទាក់ទងនឹងអាណាចក្រស្រីវិជ័យ**] (ជាភាសាសៀម) នគរស្រីធម្មរាជ, មជ្ឈមណ្ឌលវប្បធម៌នៃភូមិភាគខាងត្បូង, ព.ស. ២៥២៥ គ.ស. ១៩៨២ ។

◎ ប្រេមិន្ទ្រ គារវី **គាំយឺមភាសាខ្មែរនៃភាសាថៃយថិ່នតៃ៎** [**ពាក្យខ្ចីភាសាខ្មែរក្នុងភាសាថៃតំបន់ខាងត្បូង**] (ជាភាសាសៀម) បាងកក, និក្ខេបបទថ្នាក់បណ្ឌិត, សាកលវិទ្យាល័យចុឡាលង្ករណ៍, ព.ស. ២៥៣៨ គ.ស. ១៩៩៥ ។

◎ ប្រោន, ម៉ាវិន ជ. [**ពីភាសាថៃបុរាណមកដល់បណ្ដាគ្រាមភាសាបច្ចុប្បន្ន និងការនិពន្ធដទៃទៀតស្ដីពីភាសាសាស្ត្រប្រវត្តិសាស្ត្រថៃ**] (ជាភាសាអង់គ្លេស) បាងកក, វ៉ៃត៍ឡូតឹស, ឆ្នាំ ១៩៨៥ ។

Brown, Marvin J., *From Ancient Thai to Modern Dialects and Other Writings on Historical Thai Linguistics*, Bangkok, White Lotus, 1985.

◎ ពិនិច្ច វណ្ណដ៉ាម **លិលិតព្រះលូ ការសឹក្សាជើងប្រវ័ត** [លិលិតព្រះល ការសិក្សាផ្នែកប្រវត្តិ] (ជាភាសាសៀម) បាងកក, ព.ស. ២៥៣៥ គ.ស. ១៩៩២ ។

◎ ពិរិយៈ ក្រៃបុក្ស [**សិល្បៈក្នុងភូមិភាគខាងត្បូងនៃប្រទេសថៃមុនគ្រិស្តសតវត្សរ៍ទី ១៤**] (ជាភាសាអង់គ្លេស) បាងកក, ផ្នែកសិល្បាករ, ឆ្នាំ ១៩៨១ ។

Piriya Krairiksh, *Art in Peninsular Thailand prior to the fourteenth century AD.*, Bangkok, Fine Arts Department, 1981.

◎ ពេជ្រ ទុំក្រវិល **ស្បែកពណ៌ និង ស្បែកតូច** (ជាភាសាខ្មែរ និង អង់គ្លេស) [ភ្នំពេញ], [ឆ្នាំ ២០០០] ។

◎ ពៅ សាវរស **វចនានុក្រមខ្មែរចាស់_បារាំង_អង់គ្លេស** ប៉ារីស, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ, ឆ្នាំ ១៩៩២ ។

◎ ម៉ារស្គាល, ហង់រី « [កំណត់ត្រាអំពីក្រុមណាំងស្បែកមួយ] » (ជាភាសាបារាំង) ក្នុង [**ព្រឹត្តិបត្រនៃសមាគមសិក្សាឥណ្ឌូចិន**] លេខ ៣៣, ឆ្នាំ ១៩៥៨, ទំព័រ ២៥១-២៦០ ។

Marchal, Henri, « Notes sur un théâtre d'ombres », *BSEI*, XXXIII, 1958, pp. 251-260.

◎ លី ធាមតេង **កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា បកប្រែផ្ទាល់ពីឯកសារដើមភាសាចិន** ភ្នំពេញ, ចាត់ចែងបកប្រែដោយ លី ធាមតេង ដោយមានជំនួយពី អ៊ឹង ឡាយ, តាំង ស៊ុយគង់ និង ម៉ា អៀង, បោះពុម្ពលើកទី ៣, ព.ស.២៥១៦ គ.ស.១៩៧៣ ។

◎ វិឃើរី, ម៉ៃខឹល « [ការបកស្រាយឡើងវិញនូវចារឹកខ្មែរនៃតំបន់តៈណាវស្រី] » (ជាភាសាអង់គ្លេស) ក្នុង [**ទស្សនាវដ្ដីស្យាមសមាគម**] លេខ ៦១ (១), ខែមករា ឆ្នាំ ១៩៧៣, ទំព័រ ៥១-៧០ ។

Vickery, M., "The Khmer Inscriptions of Tenasserim: A Reinterpretation", *Journal of The Siam Society*, Vol. LXI, 1 (January), 1973, pp. 51-70.

◎ វិឃើរី, ម៉ៃខឹល « [សិលាចារឹកព្រះបាទរាមកំហែង៖ ដំណែលក្លែងក្លាយនៃប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ឬទេ ?] » (ជាភាសាអង់គ្លេស) ក្នុង [**ការជជែកតវ៉ាគ្នាអំពីសិលាចារឹកព្រះបាទរាមកំហែង ។ អត្ថបទប្រមូល**] (ជាភាសាអង់គ្លេស) បាងកក, ស្យាមសមាគម, ឆ្នាំ ១៩៩១, ទំព័រ ៣-៥១ ។

Vickery, Michael, "The Ram Khamhaeng Inscription: A Piltdown Skull of Southeast Asian History?", *The Ramkhamhaeng Controversy, Collected Papers*, Bangkok, The Siam Society, 1991, pp. 3-51.

◎ វិឃើរី, ម៉ៃខឹល « [ដំណែលក្លែងក្លាយ៖ ការតែងតាំងទី ២ ។ កំណត់សម្គាល់ជូនចំពោះក្រុមពិភាក្សាអំពីសិលាចារឹកព្រះបាទរាមកំហែង] » (ជាភាសាអង់គ្លេស) ក្នុង [**ការជជែកតវ៉ាគ្នាអំពីសិលាចារឹកព្រះបាទរាមកំហែង ។ អត្ថបទប្រមូល**] (ជាភាសាអង់គ្លេស) បាងកក, ស្យាមសមាគម, ឆ្នាំ ១៩៩១, ទំព័រ ៣៣៣-៤១៨ ។

Vickery, Michael, "Piltdown Skull: Installment Two. Remarks offered to the Ram Khamhaeng Panel", *The Ramkhamhaeng Controversy, Collected Papers*, Bangkok, The Siam Society, 1991, pp. 333-418.

◎ វិឃើរី, ម៉ៃខឹល « [ប្រទេសកម្ពុជានិងប្រទេសជិតខាងក្នុងសតវត្សរ៍ទី ១៥] » (ជាភាសាអង់គ្លេស) [**អត្ថបទការងារនៃវិទ្យាស្ថានស្រាវជ្រាវអាស៊ី**] លេខ ២៧, ខែមិថុនា ឆ្នាំ ២០០៤, www.ari.nus.edu.sg/pub/ wps.htm ។

Vickery, Michael, "Cambodia and Its Neighbors in the 15th Century", ARI Working Paper, No. 27, June 2004, www.ari.nus.edu.sg/pub/wps.htm.

◎ វីទ្វេយ៍, ប៉ូល [**ខែស្វូនៃសមាស៖ ការសិក្សាភូមិសាស្ត្រផ្នែកប្រវត្តិសាស្ត្រអំពីជ្រោយម៉ាឡាយូមុនគ.ស. ១៥០០**] (ជាភាសាអង់គ្លេស) គូឡាឡាំពួរ, រោងពុម្ពសាកលវិទ្យាល័យម៉ាឡាយ៉ា, ឆ្នាំ ១៩៦៥ (ការបោះពុម្ពលើកទី ១៖ ឆ្នាំ ១៩៦១) ។

Wheatley, Paul, *The Golden Khersonese: studies in the historical geography of the Malay Peninsula before A.D. 1500*, Kuala Lumpur, University of Malaya Press, 1965 (1st edition: 1961).

◎ *វ៉ុល្ទ័រ្ស, អូ.ដាប៊ឺលយូ. « [តាំព្រលិង្គ] » (ជាភាសាអង់គ្លេស) ក្នុង* **[ព្រឹត្តិប័ត្រនៃសាលាសិក្សាបូព៌ាប្រទេសនិងអាហ្វ្រិក]** *លេខ ២១ (៣), ឆ្នាំ ១៩៥៨, ទំព័រ ៥៨៧-៦០៧ ។*

Wolters, O.W., "Tāmbraliṅga", *Bulletin of the School of Oriental and African Studies*, XXI (3), 1958, pp. 587-607.

◎ *សេដែស, ហ្សក « [អាណាចក្រស្រីវិជ័យ] » (ជាភាសាបារាំង) ក្នុង* **[ព្រឹត្តិប័ត្រនៃសាលាបារាំងសែសចុងបូព៌ាប្រទេស]** *លេខ ១៨, ឆ្នាំ ១៩១៨, ទំព័រ ១-៣៦ ។*

Cœdès, George, « Le royaume de Çrîvijaya », *BEFEO*, XVIII, 1918, pp. 1-36.

◎ *សេដែស, ហ្សក* **[ប្រជុំសិលាចារឹកស្យាម ។ ភាគទី ២៖ សិលាចារឹកទ្វារវតី ស្រីវជ័យ និង លវោ]** *(ជាភាសាបារាំង និងសៀម) បាងកក, រោងពុម្ពបាងកកថៃម្ស៍ ឆ្នាំ ១៩២៩ ។*

Cœdès, George, *Recueil des inscriptions du Siam. Deuxième partie : Inscriptions de Dvāravatī, de Çrīvijaya et de Lăvo*, Bangkok, Bangkok Times Press, 1929.

◎ *សេដែស, ហ្សក* **[ប្រជាជនទាំងឡាយក្នុងជ្រោយឥណ្ឌូចិន]** *(ជាភាសាបារាំង) ប៉ារីស, ឌុយណូដ៍, ឆ្នាំ ១៩៦២ ។*

Cœdès, George, *Les Peuples de la Péninsule indochinoise*, Paris, Dunod, 1962.

◎ *សេដែស, ហ្សក* **[រដ្ឋនានាដែលបានទទួលវប្បធម៌ហិណ្ឌូក្នុងឥណ្ឌូចិន និងឥណ្ឌូណេស៊ី]** *(ជាភាសាបារាំង) ប៉ារីស, ដឺបុក្ការដ៍, ឆ្នាំ ១៩៨៩ (ការបោះពុម្ពឡើងវិញ, ការបោះពុម្ពផ្សាយលើកទី ៣ ដោយមានការពិនិត្យឡើងវិញ និងផ្តល់ពត៌មានថ្មីៗ៖ ឆ្នាំ ១៩៦៤ ប៉ារីស, ដឺបុក្ការដ៍) ។*

Cœdès, George, *Les États hindouisés d'Indochine et d'Indonésie*, Paris, De Boccard, 1989 (reprint, 3rd edition reviewed and updated: 1964, Paris, De Boccard).

◎ *សំណាក់នាយករដ្ឋមន្ត្រី* **ប្រះជុំព្រះតាំរាបរមរាជូទិគញ្ញើគល្បនា សម័យអយុធ្យា ភាគ ១ [ប្រជុំព្រះតម្រាបរមរាជូទ្ទិសដើម្បីកល្បនា សម័យអយុធ្យា ភាគទី ១]** *(ជាភាសាសៀម) បាងកក, សំណាក់នាយករដ្ឋមន្ត្រី, ព.ស. ២៥១០ គ.ស. ១៩៦៧ ។*

◎ *ស្គីត, វ៉ាល់ទ័រ វិល្លៀម, និង ស្ហាល អូត្តូ ប្លាក់ដឹន* **[ជនជាតិសៃយសាសន៍ទាំងឡាយក្នុងជ្រោយមឡាយូ]** *(ជាភាសាអង់គ្លេស) ភាគទី ១ និងទី ២, ឡុងដ្រ៍, ម៉ាក់មីល្ល៉ាន់និងក្រុម ចំកាត់, ឆ្នាំ ១៩០៦ ។*

Skeat, W.W., C.O. Blagden, *Pagan Races of the Malaysian Peninsula*, Vol. I and II, London, Macmillan and Co., Limited, 1906.

◎ *ស្ថាប័នទក្សិណគតីសិក្សា* **ពចនានុក្រមភាសាថិ៉នតៃ ២៥២៥ [វចនានុក្រមភាសាតំបន់ខាងត្បូង ព.ស. ២៥២៥]** *(ជាភាសាសៀម) បាងកក, ស្ថាប័នទក្សិណគតីសិក្សា, ព.ស. ២៥២៥ គ.ស. ១៩៨២ ។*

◎ *ស្ថាប័នទក្សិណគតីសិក្សា* **ប្រះវ័តិគាស្ដ្រលេះបោរាណគឌីគាបសមុទ្រស្ទិងព្រះ [ប្រវត្តិសាស្ត្រនិងបុរាណខទ្យានៀបកោះស្ទឹងព្រះ]** *(ជាភាសាសៀម) បាងកក, ស្ថាប័នទក្សិណគតីសិក្សា សាកលវិទ្យាល័យស្រីនគរិន្ទ្រវិរោឍ (បណ្ណាធិការ៖ លោក ស្ថាពរ ស្រីសច្ចំ), ព.ស. ២៥២៨ គ.ស. ១៩៨៥ ។*

◎ *ស្ថាប័នទក្សិណគតីសិក្សា* **សារានុក្រមវ័ឍនធររមភាគតៃ [សារានុក្រមអារ្យធម៌ភាគខាងត្បូង]** *(ជាភាសាសៀម) ៩ ភាគ, បាងកក, ស្ថាប័នទក្សិណគតីសិក្សា, ព.ស. ២៥២៩ គ.ស. ១៩៨៦ ។*

៙ ស្ហត្តុំ, ហ.ល. [**វចនានុក្រមចារឹកមនពីសតវត្សរ៍ទី ៦ ដល់ទី ១៦**] *(ជាភាសាអង់គ្លេស) ឡុងដ្រ៍, រោងពុម្ព សាកលវិទ្យាល័យអុកស្ហ្វដ៍, ឆ្នាំ ១៩៧១ ។*

Shorto, H.L., *A Dictionary of the Mon Inscriptions from the Sixth to the Sixteenth Centuries*, London, Oxford University Press, 1971.

៙ *ហ៊ុល្ហ្ស, អ៊ឺ. « [កំណត់អំពីចារឹកទមិឡមួយនៅប្រទេសសៀម] » (ជាភាសាអង់គ្លេស) ក្នុង* [**ទស្សនាវដ្ដីរាជសមាគមអាស៊ី**] *ឆ្នាំ ១៩១៣, ទំព័រ ៣៣៧-៣៣៩ ។*

Hultzsch, E., "Note on a Tamil Inscription in Siam", *Journal of the Royal Asiatic Society*, 1913, pp. 337-339.

៙ *ហ៊ុល្ហ្ស, អ៊ឺ. « [កំណត់បន្ថែមអំពីចារឹកទមិឡមួយនៅប្រទេសសៀម] » (ជាភាសាអង់គ្លេស) ក្នុង* [**ទស្សនាវដ្ដីរាជសមាគមអាស៊ី**] *ឆ្នាំ ១៩១៤, ទំព័រ ៣៩៧-៣៩៨ ។*

Hultzsch, E., "Supplementary Note on a Tamil Inscription in Siam", *Journal of the Royal Asiatic Society*, 1914, pp. 397-398.

៙ *ហេម្មេ៉ត, គ្រីស្ទីន « [ល្ខោននោរានៅភាគខាងត្បូងនៃប្រទេសថៃ ÷ ការគោរពបូជាដូនតា] » (ជាភាសាបារាំង) ក្នុង* **ព្រឹត្តប័ត្រនៃ ស.ប.ច.ប.ប.** *លេខ ៧៩.២, ឆ្នាំ ១៩៩២, ទំព័រ ២៦១-២៨២ ។*

Hemmet, Christine, « Le Nora du sud de la Thaïlande : un culte aux ancêtres », *BEFEO*, 79.2, 1992, pp. 261-282.

៙ *ហេម្មេ៉ត, គ្រីស្ទីន « [ពួកបក្សតាយ: ជនជាតិថៃដែលកាន់ព្រះពុទ្ធសាសនាក្នុងជ្រោយមឡាយូ] » (ជាភាសាបារាំង) ក្នុង* **ប៉េណាំងស៊ុល** *លេខ ២៩ (២), ឆ្នាំ ១៩៩៤, ទំព័រ ៩៨-១២៩ ។*

Hemmet, Christine, « Les Pak Tay : Thaïs bouddhistes de la péninsule malaise », *Péninsule*, 29 (2), 1994, pp. 98-129.

៙ *ហ្គីយ៉ុង, អេម៉្មានុយអែល* [**ជនជាតិមន ÷ អារ្យធម៌មួយនៅអាស៊ីអាគ្នេយ៍**] *(ជាភាសាអង់គ្លេស) បាងកក, ស្យាមសមាគម, ឆ្នាំ ១៩៩៩ ។*

Guillon, Emmanuel, *The Mons: A Civilization of Southeast Asia*, Bangkok, The Siam Society, 1999.

៙ *ហ្វែរ៉ង់ដ៍, ហ្គាប្រ៊ីយែល « [ចក្រភពស្រីវិជ័យនៅកោះស៊ុម៉ាត្រា] » (ជាភាសាបារាំង) ក្នុង* [**ទស្សនាវដ្ដីអាស៊ី**] *ឆ្នាំ ១៩២២, កក្កដា-កញ្ញា ទំព័រ ១-១០៤, តុលា-ធ្នូ ទំព័រ ១៦១-២៤៦ ។*

Ferrand, Gabriel, « L'empire sumatranais de Śrī Vijaya », *Journal Asiatique*, juill.-sept., pp. 1-104, oct.-déc. pp. 161-246, 1922.

៙ *ហ្សាក់, ក្លូដ « [ហ្វូណន, ចេនឡា, ស្រីវិជ័យ] » (ជាភាសាបារាំង) ក្នុង* **សន្និសីទបារាំង-ថៃ ទី ៣** *បាងកក, សាកលវិទ្យាល័យសិល្បាករ, ឆ្នាំ ១៩៩៨, ទំព័រ ១៤-២៣ ។*

Jacques, Claude, « Funan, Zhenla, Srîvijaya », in *$3^{e}$ Symposium franco-thaï*, Bangkok, Silapakorn University, 1998, pp. 14-23.

៙ *ហ្សាក់-ហ៊ែរហ្គូអាល់ក៍, មីស្ហែល, ធរាពង្ស ស្រីសុជាតិ, និង ទិវា សុភចយ៉ា « [ភូមិភាគនគរស្រីធម្មរាជពីសតវត្សរ៍ទី ៥ ដល់ទី ១៤] » (ជាភាសាបារាំង) ក្នុង* [**ទស្សនាវដ្ដីអាស៊ី**] *លេខ ២៨៤.២, ឆ្នាំ ១៩៩៦, ទំព័រ ៣៦១-៤៣៥ ។*

Jacq-Hergoualc'h, Michel, Tharapong Srisuchat et Thiva Supajanya, « La région de Nakhon Si Thammarat du $V^{e}$ au $XIV^{e}$ siècles », *Journal Asiatique*, 284.2, 1996, pp. 361-435.

⊙ ហ្សាក់-ហែរហ្គូអាល់ក៍, មីស្ហែល, ទិវា សុភចយ៉ា, និង វិជ្ជាពន្ធ គ្រឹស្ណពល « [ដំណាក់មួយនៅតាមផ្លូវសមុទ្រនៃជំនួញសូត្រ÷ ភាគខាងត្បូងនៃបួរដីក្រាសនៅសតវត្សរ៍ទី ៩] » (ជាភាសាបារាំង) ក្នុង **[ទស្សនាវដ្ដីអាស៊ី]** លេខ ២៨៦.១, ឆ្នាំ ១៩៩៨, ទំព័រ ២៣៥-៣២០ ។

Jacq-Hergoualc'h, Michel, Thiva Supajanya et Wichapan Krisanapol, « Une étape de la route maritime de la soie : la partie méridionale de l'isthme de Kra au IXe siècle », *Journal Asiatique*, 286.1, 1998, pp. 235-320.

⊙ ឡុង សៀម **វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦-៨)** ភ្នំពេញ, រាជបណ្ឌិតសភាកម្ពុជា វិទ្យាស្ថានភាសាជាតិ, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មហាវិទ្យាល័យបុរាណវិទ្យា, ឆ្នាំ ២០០០, ៦៣២ ទំព័រ ។

⊙ អនន្ត អារីយ៍ពង្ស **អក្សរខ្មុម [អក្សរខម]** (ជាភាសាសៀម) សុងខ្លា, សាកលវិទ្យាល័យស្រីនគរិន្ទ្រវិរោឍ ភាគខាងត្បូង, បោះពុម្ពលើកទី ១, ព.ស. ២៥៣៨ (គ.ស. ១៩៩៥) ។

⊙ អនុមាន រាជធន (ព្រះយ៉ា) **រឿងឡោមឥន្ទោចីនសម័យបោរាណ [រឿងព្រាយឥណ្ឌូចិនសម័យបុរាណ]** (ជាភាសាសៀម) បាងកក, ផ្នែកសិល្បាករ, ស្នាដៃបោះពុម្ពឈុតសម្បូណ៌របស់សាស្ត្រាចារ្យ ព្រះយ៉ាអនុមានរាជធន **[ខស័យប្រចគ្គសាស្ត្រ-បុរាណខទ្យា]** ក្បាលទី ៣, ព.ស. ២៥៣១ គ.ស. ១៩៨៨ ។

⊙ អ៊ិងអរ បទមតិត្ត [ការធ្វើស្រែក្នុងសាត្រាបុរាណនៅស្ទឹងព្រះ ក្នុងភូមិភាគខាងត្បូងនៃប្រទេសថៃ] » (ជាភាសាបារាំង) ក្នុង **អាហ្សេអានី** លេខ ៤, ឆ្នាំ ១៩៩៩, ទំព័រ ៩៣-១២៣ ។

Ingon Patamadit, « La riziculture dans les manuscrits de sagesse traditionnelle à Sathing Phra, dans le Sud de la Thaïlande », *Aséanie*, 4, 1999, pp. 93-123.

⊙ ឧរ៉ៃស៊ី វរសរិន **[ធាតុខ្មែរក្នុងការកកើតនៃភាសាសៀម]** (ជាភាសាបារាំង) ប៉ារីស, សេឡាហ្វ, ឆ្នាំ ១៩៨៤ ។

Uraisi Varasarin, *Les Éléments khmers dans la formation de la langue siamoise*, Paris, SELAF, 1984.

⊙ អូកូន្នរ, ស្តាន់ឡេយ៍ ជូនិញរ «[សិជល÷ ទីតាំងលំនៅឋានសម័យដើមនៅភាគខាងត្បូងនៃប្រទេសថៃ]» (ជាភាសាអង់គ្លេស) ក្នុង **[ទស្សនាវដ្ដីស្យាមសមាគម]** លេខ ៥៦, ឆ្នាំ ១៩៦៨, ទំព័រ ១-១៨ ។

O'Connor, Stanley Jr., "Sichon: An Early Settlement in Peninsular Thailand", *Journal of The Siam Society*, Vol. LVI, 1968, pp. 1-18.

⊙ អូកូន្នរ, ស្តាន់ឡេយ៍ ជូនិញរ « [តាំព្រលិង្គ និង ចក្រភពខ្មែរ] » (ជាភាសាអង់គ្លេស) ក្នុង **[ទស្សនាវដ្ដីស្យាមសមាគម]** លេខ ៦៣, ឆ្នាំ ១៩៧៥, ទំព័រ ១៦១-១៧៥ ។

O'Connor, Stanley Jr., "Tambralinga and the Khmer Empire", *Journal of The Siam Society*, Vol. LXIII, 1975, pp. 161-175.

⊙ អាំង ជូលាន **[សត្វអធិធម្មជាតក្នុងសាសនាអ្នកស្រុកជាតខ្មែរ]** (ជាភាសាបារាំង) ប៉ារីស, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ, ឆ្នាំ ១៩៨៦ ។

Ang Chouléan, *Les Êtres surnaturels dans la religion populaire khmère*, Paris, Centre de documentation et de recherche sur la civilisation khmère (Cedoreck), 1986.